# តើព្រះយេស៊ូគ្រីស្ទទ្រង់ជាអ្នកណា ?

*ហេតុអ្វីគេហៅព្រះយេស៊ូជារាជបុត្រា «ច្បង» នៃព្រះ ?* (១)

*ហេតុអ្វីគេហៅទ្រង់ជា «ព្រះបន្ទូល» ?* (១)

*ហេតុអ្វីបានជាព្រះយេស៊ូយាងមកផែនដីជាមនុស្ស ?* (២-៤)

*ហេតុអ្វីទ្រង់ធ្វើអព្ភូតហេតុ ?* (៥)

*តើព្រះយេស៊ូនឹងប្រព្រឹត្តអ្វីក្នុងពេលអនាគតឆាប់ៗខាងមុខនេះ ?* (៦)



១. ព្រះយេស៊ូបានគង់នៅក្នុងស្ថានសួគ៌ជាបុគ្គលវិញ្ញាណមុនពេលទ្រង់យាងចុះមកផែនដី ។ ទ្រង់ជាបុគ្គលមុនគេបង្អស់ដែលព្រះបានបង្កើត ហើយដូច្នេះគេក៏ហៅទ្រង់ជារាជបុត្រា «ច្បង» នៃព្រះ ។ (កូល៉ុស ១:១៥; វិវរណៈ ៣:១៤) ព្រះយេស៊ូជាបុត្រាតែមួយគត់ដែលព្រះបានបង្កើតដោយអង្គទ្រង់ ។ ព្រះយេហូវ៉ាបានប្រើព្រះយេស៊ូមុនទ្រង់ចាប់កំណើតជាមនុស្ស ឲ្យធ្វើជា «មេជាង» ក្នុងការបង្កើតអស់ទាំងរបស់ឯទៀតក្នុងស្ថានសួគ៌និងផែនដី ។ (សុភាសិត ៨:២២-៣១; កូល៉ុស ១:១៦, ១៧) ព្រះអង្គក៏បានប្រើទ្រង់ធ្វើជាមេនាំពាក្យរបស់ព្រះអង្គដែរ ។ ហេតុនេះហើយបានជាគេហៅព្រះយេស៊ូជា «ព្រះបន្ទូល» នោះ ។—យ៉ូហាន ១:១-៣; វិវរណៈ ១៩:១៣

២. ព្រះបានចាត់រាជបុត្រាទ្រង់ឲ្យមកផែនដី ដោយបញ្ចូលជីវិតរាជបុត្រាទៅក្នុងផ្ទៃនៃនាងម៉ារា ។ ដូច្នេះព្រះយេស៊ូឥតមានបិតាជាមនុស្សនោះទេ ។ ហេតុនេះហើយបានជាទ្រង់ឥតមានសេចក្ដីបាបឬសេចក្ដីឥតគ្រប់លក្ខណ៍ណាជាប់មកតាមពូជសោះឡើយ ។ ព្រះបានចាត់ឲ្យព្រះយេស៊ូមកផែនដីសំរាប់មូលហេតុបីយ៉ាង៖ (១) បង្រៀនយើងនូវសេចក្ដីពិតអំពីព្រះ (យ៉ូហាន ១៨:៣៧) (២) កាន់ជាប់នឹងសេចក្ដីស្មោះត្រង់ដ៏ពេញលក្ខណៈ ទុកជាគំរូឲ្យយើងប្រព្រឹត្តតាម (ពេត្រុសទី១ ២:២១) និង (៣) បូជាជីវិតទ្រង់ដើម្បីដោះលែងយើងឲ្យរួចពីសេចក្ដីបាបនិងសេចក្ដីស្លាប់ ។ ហេតុអ្វីក៏ត្រូវការសេចក្ដីនេះ ?—ម៉ាថាយ ២០:២៨

៣. ដោយមិនស្ដាប់តាមបង្គាប់នៃព្រះ អ័ដាមជាបុរសទីមួយបានប្រព្រឹត្តអំពើដែលព្រះគម្ពីរហៅថា «បាប» ។ ដូច្នេះ ព្រះបានកាត់ទោសគាត់ដល់ជីវិត ។ (លោកុប្បត្តិ ៣:១៧-១៩) គាត់លែងមានគុណសម្បត្តិស្មើដល់បមាណីយនៃព្រះ ដូច្នេះគាត់ក៏លែងមានសេចក្ដីគ្រប់លក្ខណ៍ទៀតដែរ ។ បន្តិចម្ដងៗ គាត់ក៏បានទៅជាចាស់ជរាហើយត្រូវស្លាប់ទៅ ។ អ័ដាមបាននាំយកសេចក្ដីបាបឆ្លងមកដល់កូនចៅទាំងអស់របស់គាត់ ។ ហេតុនេះហើយបានជាយើងទៅជាចាស់ជរា មានជម្ងឺឈឺថ្កាត់ ហើយត្រូវស្លាប់ទៅដែរ ។ តើមនុស្សជាតិអាចបានសង្គ្រោះយ៉ាងដូចម្ដេច ?—រ៉ូម ៣:២៣; ៥:១២



***កិច្ចបំរើរបស់ព្រះយេស៊ូ មានរួម ការបង្រៀន ការធ្វើអព្ភូតហេតុ ព្រមទាំងការបូជាជីវិតទ្រង់សំរាប់យើងផង***



៤. ព្រះយេស៊ូគឺជាមនុស្សគ្រប់លក្ខណ៍មួយរូបដូចអ័ដាមអញ្ចឹងដែរ ។ ប៉ុន្តែ ខុសពីអ័ដាម ព្រះយេស៊ូបានស្តាប់បង្គាប់ដល់ព្រះយ៉ាងត្រឹមត្រូវឥតខ្ចោះ សូម្បីក្រោមការសាកល្បងដ៏ពិបាកជាទីបំផុត ។ ដូច្នេះ ទ្រង់អាចបូជាជីវិតរបស់ទ្រង់ជាមនុស្សគ្រប់លក្ខណ៍ ដើម្បីលោះបាបរបស់អ័ដាម ។ នេះជាអ្វីដែលព្រះគម្ពីរហៅថា ‹តម្លៃលោះ› ។ កូនចៅរបស់អ័ដាមអាចត្រូវដោះលែងឲ្យបានរួចខ្លួនពីការកាត់ទោសដល់ជីវិត ។ អស់អ្នកដែលមានជំនឿលើព្រះយេស៊ូអាចទទួលសេចក្ដីអត់ឱនទោសសំរាប់បាបរបស់ខ្លួន ហើយអាចទទួលជីវិតអស់កល្បជានិច្ចផង ។—ធីម៉ូថេទី១ ២:៥, ៦; យ៉ូហាន ៣:១៦; រ៉ូម ៥:១៨, ១៩

៥. កាលទ្រង់គង់នៅលើផែនដី ព្រះយេស៊ូបានព្យាបាលពួកមនុស្សឈឺ ផ្ដល់ចំណីដល់ពួកអ្នកស្រេកឃ្លាន ហើយធ្វើឲ្យខ្យល់ព្យុះស្ងប់បាត់ទៅ ។ ទ្រង់បានទាំងប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញផង ។ ហេតុអ្វីទ្រង់ធ្វើអព្ភូតហេតុ ? (១) ទ្រង់មានព្រះទ័យអាណិតអាសូរដល់មនុស្សដែលកំពុងឈឺចាប់ ហើយទ្រង់ចង់ជួយពួកគេ ។ (២) អព្ភូតហេតុរបស់ទ្រង់បង្ហាញជាភស្តុតាងថា ទ្រង់ពិតជារាជបុត្រានៃព្រះ ។ (៣) អព្ភូតហេតុទាំងនេះបង្ហាញនូវអ្វីដែលទ្រង់នឹងប្រព្រឹត្តចំពោះមនុស្សលោកដែលស្ដាប់បង្គាប់ ពេលទ្រង់គ្រប់គ្រងជាព្រះមហាក្សត្រទៅលើផែនដី ។—ម៉ាថាយ ១៤:១៤; ម៉ាកុស ២:១០-១២; យ៉ូហាន ៥:២៨, ២៩

៦. ព្រះយេស៊ូបានសោយទិវង្គតហើយបានត្រូវព្រះប្រោសឲ្យមានព្រះជន្មរស់ឡើងវិញ ជារូបវិញ្ញាណមួយ ហើយទ្រង់បានយាងត្រឡប់ទៅស្ថានសួគ៌វិញ ។ (ពេត្រុសទី១ ៣:១៨) តាំងពីគ្រានោះមក ព្រះអង្គបានលើកទ្រង់ឲ្យសោយរាជ្យជាព្រះមហាក្សត្រ ។ មិនយូរទេ ព្រះយេស៊ូនឹងដកយកអស់ទាំងអំពើអាក្រក់និងការឈឺចាប់ចេញពីផែនដីនេះ ។—ទំនុកដំកើង ៣៧:៩-១១; សុភាសិត ២:២១, ២២

